**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.** –

អនុក្រឹត្យនេះមានគោលបំណងកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅនៃ **មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ** ដើម្បីលើកកម្ពស់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចនៅថ្នាក់ក្រោមជាតិដោយផ្តល់ហិរញ្ញប្បទានទៅដល់គម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈយុទ្ធសាស្ត្រ និងផ្តល់ការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីលើកកម្ពស់ការបំពេញភារកិច្ច និងការគ្រប់គ្រងការវិនិយោគសាធារណៈឱ្យកាន់តែប្រសើរ។

**មាត្រា ២.** –

អនុក្រឹត្យនេះមានគោលដៅកំណត់ពីក្របខ័ណ្ឌគតិយុត្តសម្រាប់គ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**មាត្រា ៣.** –

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើការគ្រប់គ្រង និងចាត់ចែងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់ហិរញ្ញប្បទានដល់គម្រោងវិនិយោគសាធារណៈដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការកំណត់អាទិភាពថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តត្រូវសម្រេចដោយក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី២

## ប្រភពធនធាន

**មាត្រា ៤.** –

ប្រភពធនធាននៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន÷

- ការចូលរួមចំណែកពីចំណូលចរន្តនៃថវិកាជាតិ
- ការចូលរួមចំណែកពីដៃគូអភិវឌ្ឍន៍ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានាក្រោមក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការ
- ការចូលរួមចំណែកធនធានពីប្រភពផ្សេងៗទៀត ។

**មាត្រា ៥.** –

ប្រភពធនធានដូចមានចែងក្នុងមាត្រា ៤ ត្រូវបានប្រើប្រាស់ស្របតាមគោលការណ៍ និងនីតិវិធីដូចបានកំណត់នៅក្នុងអនុក្រឹត្យនេះ។ ក្នុងករណីដៃគូអភិវឌ្ឍន៍មានបំណងផ្តល់ធនធានសម្រាប់មុខសញ្ញា ឬគោលបំណងជាក់លាក់ណាមួយត្រូវអនុវត្តតាមបទប្បញ្ញត្តិដោយឡែកផ្អែកលើកិច្ចព្រមព្រៀងរវាងក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍។

**មាត្រា ៦.-**

កម្រិតនៃការផ្ទេរធនធានពីថវិកាជាតិទៅក្នុងគណនីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់សម្រាប់ថេរៈវេលាចំនួនប្រាំ(០៥)ឆ្នាំ លើមូលដ្ឋានក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនៃថវិកាទូទៅរបស់រដ្ឋ។

កម្រិតនៃការផ្ទេរពីថវិកាជាតិទៅក្នុងគណនីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០១៦ ដល់ ឆ្នាំ២០២០ មានដូចខាងក្រោម ៖

- សម្រាប់ឆ្នាំថវិកា២០១៦ មានចំនួន ០,០២ ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១៥
- សម្រាប់ឆ្នាំថវិកា២០១៧ មានចំនួន ០,០៤ ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១៦
- សម្រាប់ឆ្នាំថវិកា២០១៨ មានចំនួន ០,០៥ ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១៧
- សម្រាប់ឆ្នាំថវិកា២០១៩ មានចំនួន ០,០៦ ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១៨
- សម្រាប់ឆ្នាំថវិកា២០២០ មានចំនួន ០,០៧ ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១៩។

សម្រាប់ឆ្នាំ២០១៦ ធនធានដែលបានផ្ទេរពីថវិកាជាតិត្រូវបានប្រើប្រាស់ទាំងស្រុងសម្រាប់រ៉ាប់រងការចំណាយប្រតិបត្តិការរដ្ឋបាលទូទៅរបស់លេខាធិការដ្ឋានគ.វ.ក។ ចាប់ពីឆ្នាំ២០១៧ដល់ឆ្នាំ២០២០ ការចំណាយសម្រាប់សមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅរបស់លេខាធិការដ្ឋានគ.វ.កមិនត្រូវលើស ៣០ ភាគរយ នៃធនធានដែលផ្ទេរពីថវិកាជាតិ។

កញ្ចប់ថវិកានៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិគឺជាផ្នែកមួយនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំដែលត្រូវគ្រប់គ្រងផ្ទាល់ដោយក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ និងមានប្រធានលេខាធិការដ្ឋានគ.វ.កជាអាណាប័ក។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបោះផ្សាយអាណត្តិផ្ទេរធនធានជាដំណាក់ៗ ពីគណនីថវិកាជាតិទៅគណនីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបើកនៅរតនាគារជាតិ។

**មាត្រា ៧. –**

ធនធាននៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានចាត់ចែង និងគ្រប់គ្រងតាមរយៈគណនីមួយដែលត្រូវបើកនៅរតនាគារជាតិ។ គណនីនេះត្រូវឆ្លុះបញ្ចាំងនូវរាល់ប្រតិបត្តិការចំណូលដែលបានមកពីគ្រប់ប្រភពធនធានទាំងអស់នៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិដូចបានកំណត់ក្នុងមាត្រា៨នៃអនុក្រឹត្យនេះ ប្រតិបត្តិការចំណាយដែលបានផ្ទេរទៅក្នុងគណនីរដ្ឋបាលថ្នាក់ក្រោមជាតិ និងការទូទាត់ចំណាយរបស់លេខាធិការដ្ឋាន គ.វ.ក ពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ៨.** –

សមតុល្យចុងឆ្នាំរបស់គណនីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវយោងទៅឆ្នាំបន្ទាប់។

## ជំពូកទី៣
## ការគ្រប់គ្រងមូលនិធិ

**មាត្រា ៩.** –

ក្រុមប្រឹក្សាភិបាលមួយត្រូវបានបង្កើតឡើងដោយឲ្យឈ្មោះថា **ក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ** សរសេរជាអក្សរកាត់ថា **ក.វ.ក** ដើម្បីគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ១០.** –

ក.វ.ក មានសមាសភាពដូចខាងក្រោម÷

- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — ប្រធាន
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — អនុប្រធាន
- តំណាងក្រសួងមហាផ្ទៃ — អនុប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី — សមាជិក
- តំណាងលេខាធិការដ្ឋានគ.ជ.អ.ប — សមាជិក
- តំណាងក្រសួងផែនការ — សមាជិក
- តំណាងក្រសួងអភិវឌ្ឍន៍ជនបទ — សមាជិក
- តំណាងក្រសួងមុខងារសាធារណៈ — សមាជិក
- តំណាងក្រសួងកិច្ចការនារី — សមាជិក
- តំណាងក្រសួងបរិស្ថាន — សមាជិក
- តំណាងក្រសួងសាធារណៈការ និងដឹកជញ្ជូន — សមាជិក
- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ — សមាជិក
- តំណាងក្រសួងអប់រំ យុវជន និងកីឡា — សមាជិក
- តំណាងក្រសួងសុខាភិបាល — សមាជិក
- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ — សមាជិក
- តំណាងក្រសួងធនធានទឹក និងឧតុនិយម — សមាជិក
- តំណាងក្រសួងរ៉ែ និងថាមពល — សមាជិក
- តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម — សមាជិក
- តំណាងសមាគមក្រុមប្រឹក្សារាជធានី ខេត្ត — សមាជិក
- តំណាងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ — សមាជិក
- ប្រធានលេខាធិការដ្ឋាន ក.វ.ក — លេខាធិការ

ក.វ.ក អាចអញ្ជើញតំណាងនៃក្រសួង-ស្ថាប័ន អាជ្ញាធរ អង្គភាព ឬអ្នកពាក់ព័ន្ធផ្សេងៗទៀត ដើម្បីចូលរួមក្នុងកិច្ចប្រជុំ ពិភាក្សា ឬសហការការងារតាមការចាំបាច់។

**មាត្រា ១១.** –

គ.វ.ក មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- បង្កើតក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់គម្រោងវិនិយោគសាធារណៈ ដោយរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របទៅនឹងគោលនយោបាយរួមរបស់រាជរដ្ឋាភិបាលស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- អនុម័តសេចក្តីព្រាងស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន គ.វ.ក
- កំណត់លក្ខណៈសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- កំណត់លក្ខខណ្ឌវិនិច្ឆ័យសម្រាប់វាយតម្លៃលើគម្រោងវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងវាយតម្លៃអំពីសង្គតិភាព និងភាពគ្រប់ជ្រុងជ្រោយ ព្រមទាំងប្រសិទ្ធភាពនៃការប្រើប្រាស់មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យស្របទៅនឹងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីគោលនយោបាយនានារបស់រាជរដ្ឋាភិបាល
- ផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលអំពីកម្រិតជាភាគរយនៃចំណែកចូលរួមពីថវិកាជាតិទៅក្នុងធនធានមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ និងការកំណត់អាទិភាពថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុម័តសមាសភាគសម្រាប់វិនិយោគផ្ទេរអោយរដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុម័តសៀវភៅណែនាំស្តីពីប្រតិបត្តិការរបស់មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ និងរាល់ការកែតម្រូវសៀវភៅ
- ត្រួតពិនិត្យ និងអនុម័តផែនការសកម្មភាពប្រចាំឆ្នាំរបស់លេខាធិការដ្ឋានគ.វ.ក គម្រោងវិនិយោគប្រចាំឆ្នាំ និងថវិកាប្រចាំឆ្នាំរបស់មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
- ត្រួតពិនិត្យ និងអនុម័តរបាយការណ៍វឌ្ឍនភាព និងស្ថានភាពហិរញ្ញវត្ថុរបស់មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិប្រចាំត្រីមាស និងប្រចាំឆ្នាំ។ របាយការណ៍អនុវត្តទាំងនេះត្រូវផ្ញើជូនរាជរដ្ឋាភិបាល គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ទីភ្នាក់ងារ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា
- ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកានៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
- ត្រួតពិនិត្យ និងវាយតម្លៃការបំពេញភារកិច្ចរបស់លេខាធិការដ្ឋាន គ.វ.ក និងចាត់វិធានការតាមការចាំបាច់ដើម្បីធានាថាលេខាធិការដ្ឋានគ.វ.ក ប្រតិបត្តិទៅតាមអាណត្តិកិច្ចរបស់ខ្លួន
- ធានាឱ្យមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនូវការអនុវត្តមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
- ធានាឱ្យមានការផ្សព្វផ្សាយទូលំទូលាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធតាមរយៈប្រព័ន្ធផ្សព្វផ្សាយ បោះផ្សាយ និងអេឡិចត្រូនិកអំពី÷
  - ក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រ សម្រាប់គម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ការកំណត់ និងការវាយតម្លៃលើលក្ខណៈសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការកំណត់លក្ខខណ្ឌវិនិច្ឆ័យសម្រាប់វាយតម្លៃលើគម្រោងវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ទំហំធនធានសរុបនៃសមាសភាគសម្រាប់ធ្វើវិភាគទានផ្ទេរអោយរដ្ឋបាលថ្នាក់ក្រោមជាតិ រូបមន្តវិភាគ និងតួលេខវិភាជន៍បឋមឲ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិដែលនឹងទទួលបានហិរញ្ញប្បទានពីមូលនិធិ
- របាយការណ៍ហិរញ្ញវត្ថុតាមកាលកំណត់ និងរបាយការណ៍វាយតម្លៃ

• ធានាថារដ្ឋបាលថ្នាក់ក្រោមជាតិទទួលបាននូវការបណ្តុះបណ្តាល និងយល់ដឹងច្បាស់លាស់អំពីសៀវភៅណែនាំស្តីពីប្រតិបត្តិការរបស់មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ១២.** –

ក.វ.ក អាចទទួលបានហិរញ្ញប្បទានបច្ចេកទេស និងសម្ភារៈពីប្រភពក្នុងនិងក្រៅប្រទេសនានា ដើម្បីអនុវត្តអាណត្តិកិច្ចរបស់ខ្លួន។

**មាត្រា ១៣.** –

**លេខាធិការដ្ឋាននៃក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ** ដែលសរសេរកាត់ថា **លេខាធិការដ្ឋាន ក.វ.ក** ត្រូវបានបង្កើតដើម្បីបំពេញការងារប្រតិបត្តិការប្រចាំថ្ងៃរបស់ **ក.វ.ក**។ លេខាធិការដ្ឋាន ក.វ.ក មានទីតាំងស្ថិតនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ១៤ .** –

លេខាធិការដ្ឋានក.វ.ក ត្រូវដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

តំណាងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិគឺជាប្រធានលេខាធិការដ្ឋាន **ក.វ.ក** ។

ប្រធាន និងអនុប្រធានលេខាធិការដ្ឋាន**ក.វ.ក** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ **ក.វ.ក** តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ១៥ .** –

រចនាសម្ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន **ក.វ.ក** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **ក.វ.ក** ។

**មាត្រា ១៦.** –

លេខាធិការដ្ឋាន ក.វ.ក បំពេញតួនាទីជាសេនាធិការឲ្យក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ និងមានភារកិច្ចសំខាន់ៗ ដូចខាងក្រោម ÷

• សម្របសម្រួលកិច្ចការប្រចាំថ្ងៃឲ្យស្របទៅតាមគោលនយោបាយ សេចក្តីណែនាំ និងសេចក្តីសម្រេចរបស់ ក.វ.ក និងចាត់ចែង ឬ អនុវត្តសកម្មភាពអនុលោមទៅតាមនីតិវិធីរបស់មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ និងសៀវភៅណែនាំស្តីពីប្រតិបត្តិការរបស់មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានអនុម័តរួច

- រៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ផែនការហិរញ្ញប្បទានវិនិយោគប្រចាំឆ្នាំ និងថវិកាប្រចាំឆ្នាំ ដាក់ជូនក.វ.ក ដើម្បីពិនិត្យ និងអនុម័ត
- រៀបចំរបាយការណ៍វឌ្ឍនភាព និងរបាយការណ៍ហិរញ្ញវត្ថុដើម្បីដាក់ជូន ក.វ.ក ពិនិត្យ និងអនុម័ត
- រាយការណ៍ជូន ក.វ.ក នូវរាល់បញ្ហាពាក់ព័ន្ធគោលនយោបាយ ឬយុទ្ធសាស្ត្រលើការគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំ ឬកែតម្រូវ ឬធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំស្តីពីប្រតិបត្តិការរបស់មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ និងដាក់ជូន ក.វ.ក ដើម្បីពិនិត្យ និងអនុម័ត
- កៀរគរប្រភពធនធានពីក្នុង និងក្រៅប្រទេសដើម្បីធានាថាការអនុវត្តគម្រោងហិរញ្ញប្បទានវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព
- គ្រប់គ្រងហិរញ្ញវត្ថុរបស់ ក.វ.ក
- ធ្វើជាប្រតិបត្តិករនៃគម្រោង កម្មវិធីដែលគាំទ្រពីដៃគូអភិវឌ្ឍន៍នានា តាមការសម្របសម្រួលគ្នារវាងដៃគូអភិវឌ្ឍន៍ទាំងនោះ និងតាមការសម្រេចរបស់ ក.វ.ក
- ត្រូវផ្តល់ព័ត៌មានពេញលេញដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាអំពីនីតិវិធីប្រតិបត្តិការ និងសេចក្តីសម្រេចនានាពាក់ព័ន្ធនឹងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
- ត្រូវរៀបចំនិងសម្របសម្រួលការងារកសាងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងគោលបំណងលើកកម្ពស់ការប្រើប្រាស់ និងអនុវត្តគម្រោងវិនិយោគសាធារណៈប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព
- ត្រូវផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធតាមរយៈប្រព័ន្ធផ្សព្វផ្សាយ បោះផ្សាយ និងអេឡិចត្រូនិកនូវក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់គម្រោងវិនិយោគសាធារណៈដោយរដ្ឋបាលថ្នាក់ក្រោមជាតិ, ការកំណត់ និងការវាយតម្លៃលើលក្ខណៈសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ,ការកំណត់លក្ខខណ្ឌវិនិច្ឆ័យសម្រាប់វាយតម្លៃលើគម្រោងវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ, ទំហំធនធានសរុបនៃសមាសភាគសម្រាប់ធ្វើវិភាគទានផ្ទេរអោយរដ្ឋបាលថ្នាក់ក្រោមជាតិ រូបមន្តវិភាជន៍ និងតួលេខវិភាជន៍បឋមឲ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិដែលនឹងទទួលបានហិរញ្ញប្បទានពីមូលនិធិ, របាយការណ៍ហិរញ្ញវត្ថុតាមកាលកំណត់ និងរបាយការណ៍វាយតម្លៃ
- វាយតម្លៃលក្ខណៈសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលអាចចូលរួមប្រកួតប្រជែងដើម្បីទទួលបានធនធានពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
- វាយតម្លៃ និងផ្ទៀងផ្ទាត់សំណើគម្រោងវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបំពេញលក្ខខណ្ឌតម្រូវដើម្បីទទួលបានធនធានពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
- ជូនដំណឹងស្តីពីលទ្ធផលនៃការវាយតម្លៃ និងផ្ទៀងផ្ទាត់សំណើគម្រោងវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងវិនិយោគសាធារណៈដែលទទួលធនធានពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
- បំពេញការងារផ្សេងៗតាមការកំណត់របស់ ក.វ.ក ។/

**មាត្រា ១៧. –**

បុគ្គលិកបម្រើការងារប្រចាំថ្ងៃនៃលេខាធិការដ្ឋាន ក.វ.ក ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការស៊ីវិល ឬជ្រើសរើសដោយការប្រកួតប្រជែងបើកទូលាយ។ ការជ្រើសរើស បុគ្គលិកបម្រើការងារនៅក្នុងលេខាធិការដ្ឋាន ក.វ.ក ត្រូវជ្រើសរើសដោយផ្អែកលើគោលការណ៍ប្រសិទ្ធភាពការងារ សមត្ថភាព បទពិសោធន៍ និងតម្លាភាព។ មុខតំណែង លក្ខខណ្ឌការងារ នីតិវិធី និងលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ ក.វ.ក ។

**មាត្រា ១៨. –**

លើកលែងប្រធាន និងអនុប្រធាន មន្ត្រីរាជការស៊ីវិលដែលត្រូវជ្រើសរើសមកបម្រើការងារនៅក្នុងលេខាធិការដ្ឋាន ក.វ.ក ត្រូវសុំផ្អាកការងារនៅអង្គភាពដើមជាបណ្តោះអាសន្ន និងត្រូវបំពេញការងារពេញម៉ោងនៅលេខាធិការដ្ឋាន ក.វ.ក ។

**មាត្រា ១៩. –**

លេខាធិការដ្ឋាន ក.វ.ក ត្រូវស្នើសុំក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើសទីប្រឹក្សា ឬអ្នកជំនាញការជាតិ ឬអន្តរជាតិ និងបុគ្គលិកជាប់កិច្ចសន្យាដើម្បីជួយការងាររបស់លេខាធិការដ្ឋាន ក.វ.ក តាមការចាំបាច់ដោយផ្អែកលើគោលការណ៍ប្រសិទ្ធភាពការងារ សមត្ថភាព បទពិសោធន៍ និងតម្លាភាព ។

**មាត្រា ២០. –**

ក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់រាល់លិខិតផ្លូវការរបស់ក្រុមប្រឹក្សាភិបាល និងលេខាធិការដ្ឋានរបស់ខ្លួន។ ក្នុងករណីក្រុមប្រឹក្សាភិបាល និងលេខាធិការដ្ឋានពិនិត្យឃើញថាបរិមាណនៃទំហំការងារមានកាន់តែច្រើន ក្រុមប្រឹក្សាភិបាល អាចស្នើសុំបង្កើតត្រារបស់មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិផ្ទាល់ តាមនីតិវិធីដែលមានជាធរមាន។

## ជំពូកទី៤
## ការទទួលបាន ការទិញ ការប្រើប្រាស់ និងការផ្ទេរមូលនិធិ

**មាត្រា ២១. –**

ធនធាននៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ត្រូវបែងចែកជាពីរ (០២) សមាសភាគដូចខាងក្រោម÷

- សមាសភាគវិនិយោគសាធារណៈ (អភិវឌ្ឍមូលដ្ឋាន)
- សមាសភាគចំណាយប្រតិបត្តិការរដ្ឋបាលទូទៅនៃលេខាធិការដ្ឋាន ក.វ.ក។

**មាត្រា ២២. –**

សមាសភាគវិនិយោគសាធារណៈ ត្រូវបានប្រើប្រាស់សម្រាប់ផ្តល់ធនធានដល់គម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសមាសភាគចំណាយប្រតិបត្តិការរដ្ឋបាលទូទៅនៃលេខាធិការដ្ឋាន ក.វ.ក ត្រូវរ៉ាប់រងរាល់ការចំណាយទៅលើបន្ទុកបុគ្គលិក បេសកកម្ម និងរាល់ការចំណាយចាំបាច់ផ្សេងៗទៀតដើម្បីគាំទ្រដល់កិច្ចដំណើរការរបស់លេខាធិការដ្ឋាន ក.វ.ក ។ ទំហំធនធាននៃសមាសភាគនីមួយៗត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ ក.វ.ក ។

**មាត្រា ២៣.** –

រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងទទួលបានការជូនដំណឹងអំពីតួលេខវិភាជន៍បឋមពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។ លក្ខណៈសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ ក.វ.ក។

**មាត្រា ២៤.** –

ការវិភាជសមាសភាគវិនិយោគសាធារណៈប្រចាំឆ្នាំជូនរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវផ្អែកតាមរូបមន្តសមស្របដើម្បីធានាសមធម៌ និងប្រកបដោយតម្លាភាព។

**មាត្រា ២៥.** –

ការបែងចែកតួលេខវិភាជន៍បឋមនៃសមាសភាគវិនិយោគសាធារណៈ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវបែងចែកទៅតាមរូបមន្តដូចខាងក្រោម÷

- ទំហំថវិកាអប្បបរមាតាមប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក.វ.ក
- ចំណែកដែលនៅសល់ត្រូវបែងចែកទៅតាមការគណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម÷
  - ប្រជាពលរដ្ឋចំនួន ៦០ ភាគរយ ត្រូវបែងចែកទៅតាមសមាមាត្រនៃចំនួនប្រជាពលរដ្ឋនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗដោយផ្អែកតាមទិន្នន័យបច្ចុប្បន្នភាពផ្លូវការរបស់ក្រសួងផែនការ
  - សន្ទស្សន៍ភាពក្រីក្រមានចំនួន ៤០ភាគរយ ត្រូវបែងចែកទៅតាមសមាមាត្រសន្ទស្សន៍ភាពក្រីក្រដោយផ្អែកតាមទិន្នន័យបច្ចុប្បន្នភាពផ្លូវការរបស់ក្រសួងផែនការ។

**មាត្រា ២៦.** –

បន្ទាប់ពីទទួលបានការជូនដំណឹងជាផ្លូវការអំពីតួលេខវិភាជន៍បឋមពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំសំណើគម្រោងវិនិយោគសាធារណៈស្របតាមលក្ខខណ្ឌដែលបានកំណត់ និងមិនឱ្យលើសទំហំតួលេខវិភាជន៍បឋមដែលបានជូនដំណឹងនោះទេ។

ក្នុងករណីរដ្ឋបាលថ្នាក់ក្រោមជាតិពិនិត្យឃើញនូវលទ្ធភាពក្នុងការកៀរគរធនធានពីប្រភពផ្សេងទៀតសម្រាប់រៀបចំគម្រោងវិនិយោគសាធារណៈរបស់ខ្លួន រដ្ឋបាលថ្នាក់ក្រោមជាតិអាចបូកបញ្ចូលធនធានទាំងនោះជាមួយនឹងតួលេខវិភាជន៍បឋមដែលបានជូនដំណឹងពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិហើយផ្ញើមកលេខាធិការដ្ឋាន ក.វ.ក ដើម្បីវាយតម្លៃដោយផ្អែកតាមលក្ខខណ្ឌវិនិច្ឆ័យដែលបានកំណត់ដោយសេចក្តីសម្រេចរបស់ក.វ.ក។

**មាត្រា ២៧.** –

ក.វ.ក ត្រូវធ្វើការត្រួតពិនិត្យនិងកែសម្រួលឡើងវិញនូវការកំណត់លក្ខណៈសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រូបមន្តនៃការបែងចែក និងលក្ខខណ្ឌវិនិច្ឆ័យសម្រាប់វាយតម្លៃសំណើគម្រោងវិនិយោគតាមស្ថានភាពជាក់ស្តែងដើម្បីលើកកម្ពស់ឱ្យកាន់តែមានការប្រកួតប្រជែងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិបន្ទាប់ពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តរយៈពេលមិនលើសពីបី (០៣)ឆ្នាំ។

**មាត្រា ២៨.** –

ក្រោយពីមានការអនុម័តលើសំណើគម្រោងវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ធនធានមូលនិធិដែលបានវិភាជទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគឺជាចំណែកមួយនៃគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ។

**មាត្រា ២៩.** –

ការផ្ទេរធនធានវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិជូនរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវធ្វើឡើងតាមកាលវិភាគទូទាត់ដែលបានណែនាំនៅក្នុងសៀវភៅណែនាំស្តីពីប្រតិបត្តិការរបស់មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៥
## នីតិវិធីលទ្ធកម្ម និងប្រព័ន្ធទូទាត់

**មាត្រា ៣០.** –

រាល់គម្រោងវិនិយោគដែលទទួលបានហិរញ្ញប្បទានតាមរយៈមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុវត្តតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មដែលកំណត់ដោយច្បាប់និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈជាធរមាន លើកលែងតែមានបទប្បញ្ញត្តិដោយឡែក។

**មាត្រា ៣១.** –

រាល់គម្រោងវិនិយោគដែលទទួលបានហិរញ្ញប្បទានតាមរយៈមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុវត្តតាមប្រព័ន្ធ និងនីតិវិធីទូទាត់របស់រដ្ឋបាលថ្នាក់ក្រោមជាតិជាធរមាន លើកលែងតែមានបទប្បញ្ញត្តិដោយឡែក។

## ជំពូកទី៦
## ការត្រួតពិនិត្យគណនី និងកិច្ចប្រតិបត្តិការរបស់មូលនិធិ

**មាត្រា ៣២.**–

គ.វ.ក ត្រូវធានាថាយន្តការត្រួតពិនិត្យផ្ទៃក្នុងដែលមានក្នុងប្រព័ន្ធគ្រប់គ្រងត្រូវបានអនុវត្តដើម្បីសម្រេចឱ្យបានតាមគោលដៅដូចខាងក្រោម ÷

- ប្រព័ន្ធគ្រប់គ្រងដែលបានបង្កើតមានលក្ខណៈគ្រប់គ្រាន់ សមស្រប និងមានប្រសិទ្ធភាព
- ធនធានត្រូវបានប្រើប្រាស់ស្របតាមថវិកាដែលបានអនុម័តប្រចាំឆ្នាំ ព្រមទាំងស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន
- ធនធានត្រូវបានទុកដាក់ឱ្យបានត្រឹមត្រូវ មិនបាត់បង់ និងមិនប្រើប្រាស់ខុសគោលការណ៍
- ទិន្នន័យហិរញ្ញវត្ថុពិតប្រាកដត្រូវបានរៀបចំ និងលាតត្រដាងក្នុងរបាយការណ៍

គ.វ.ក ត្រូវតែងតាំងមន្ត្រីមួយរូបរបស់លេខាធិការដ្ឋាន គ.វ.ក ដើម្បីទទួលបន្ទុកជាសវនករផ្ទៃក្នុង។ សវនករផ្ទៃក្នុងត្រូវមានភារកិច្ចជួយលេខាធិការដ្ឋានគ.វ.កក្នុងការត្រួតពិនិត្យជាប្រចាំលើការងារគ្រប់គ្រងហិរញ្ញវត្ថុ ថវិកា ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមានដែលកំណត់ដោយសេចក្តីសម្រេចរបស់ គ.វ.ក។

**មាត្រា ៣៣.-**

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិជាកម្មវត្ថុសម្រាប់ការធ្វើអធិការកិច្ចហិរញ្ញវត្ថុ និងសវនកម្មរបស់ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដែលកំណត់ដោយច្បាប់។

គោលបំណងនៃការធ្វើអធិការកិច្ច និងសវនកម្ម គឺសំដៅធានាភាពជាក់លាក់ ត្រឹមត្រូវនៃព័ត៌មានហិរញ្ញវត្ថុ ការវាយតម្លៃការគ្រប់គ្រង និងនីតិវិធីហិរញ្ញវត្ថុរបស់មូលនិធិ និងការអនុវត្តគម្រោងវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ របាយការណ៍អធិការកិច្ច និងសវនកម្មដែលមានរួមបញ្ចូលនូវមតិយោបល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ លេខាធិការដ្ឋានគ.វ.ក និងអ្នកពាក់ព័ន្ធនានា ត្រូវផ្សព្វផ្សាយជាសាធារណៈ។

**មាត្រា ៣៤.-**

គណនី និងប្រតិបត្តិការរបស់មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងគណនី និងប្រតិបត្តិការថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាកម្មវត្ថុនៃការធ្វើអធិការកិច្ច និងសវនកម្មដោយអនុលោមតាមច្បាប់ជាធរមាន ។ ក្នុងករណីចាំបាច់អាចត្រូវធ្វើសវនកម្មដោយសវនករឯករាជ្យតាមការចរចារវាងដៃគូអភិវឌ្ឍន៍ដែលបានផ្តល់ហិរញ្ញប្បទានដល់មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ និងរាជរដ្ឋាភិបាល។

**មាត្រា ៣៥.-**

ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗមានសិទ្ធិពេញលេញក្នុងការពិនិត្យតាមដានលើការអនុវត្តគម្រោងវិនិយោគរបស់រដ្ឋបាលខ្លួន។ ក្នុងនាមក្រុមប្រឹក្សា អភិបាលនៃគណៈអភិបាលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធានាថា ÷

- រាល់ព័ត៌មានស្តីពីសកម្មភាព ចំនួនធនធានវិភាជន៍សម្រាប់គម្រោងវិនិយោគប្រចាំឆ្នាំ និងការប្រើប្រាស់ធនធានទាំងនោះរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយជាសាធារណៈ
- ប្រជាពលរដ្ឋត្រូវបានទទួលការលើកទឹកចិត្ត និងអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាលើការងារពាក់ព័ន្ធទៅនឹងគម្រោងវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការទទួលមតិសាធារណៈ និងការពិគ្រោះយោបល់ត្រូវបានអនុវត្តក្នុងដំណើរការការងារដែលពាក់ព័ន្ធទៅនឹងគម្រោងវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៧

## អន្តរប្បញ្ញត្តិ

**មាត្រា ៣៦. –**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវរៀបចំសម្របសម្រួលសមាសភាព គ.វ.ក ក្រោយពីអនុក្រឹត្យនេះចូលជាធរមានដើម្បីឱ្យលេខាធិការដ្ឋាន គ.វ.ក ចាប់ផ្តើមដំណើរការក្នុងឆ្នាំ២០១៦ ។

**មាត្រា ៣៧. –**

អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបំពេញមុខងារជាលេខាធិការដ្ឋាន គ.វ.ក រហូតដល់ពេលដែលលេខាធិការដ្ឋាន គ.វ.ក ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ ។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា ៣៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ និងសមាជិកដូចមានចែងនៅក្នុងមាត្រា ១០ ជាអ្នកអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៦

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

*កន្លែងទទួល ÷*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៣៩*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*